ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១.......សហវ.ទប

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែមករា ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង

## ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និង ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមជូនដំណឹងដល់ លោក លោកស្រី ដែលកំពុង ឬមានបំណងប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់អោយបានជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់អោយអនុវត្តប្រកាស លេខ ០២៨ សហវ.ប្រក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន។

ចាប់ពីពេលផ្សាយដំណឹងនេះតទៅ លោក លោកស្រី ទាំងអស់ដែលបាននិងកំពុង ឬមានបំណងប្រកបអាជីវកម្មទទួលបញ្ចាំ និងទិញ-លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា **សូមប្រញាប់មកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្ម នៅការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅរៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០១០**។ ផុតកាលវសានេះ ក្រសួងនឹងចាត់វិធានការដាក់ពិន័យតាមខ្លឹមសារដូចមានចែងក្នុងប្រកាសខាងលើ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

***<u>ទូរស័ព្ទទំនាក់ទំនង</u>***

- ***០៨៩ ៣៨៨ ៨៨៩***
- ***០១៧ ៩៩៣ ៣៦៨***
- ***០១៦ ៥៥៨ ៥៦៨***
- ***០៦៨ ៨៨៨ ៨៦៤***

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798